**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២៨១ ....សហវ.ប្រក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការផ្តល់ទឹកប្រាក់លើកទឹកចិត្តសម្រាប់ឧបត្ថម្ភជូនគណៈកម្មការអន្តរក្រសួង ចុះពិនិត្យនិងប្រមូលចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចបង់ចូលថវិការដ្ឋ

**********

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបង្កើតការប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៧  អនក្រ.បក ចុះថ្ងៃទី០៦ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-ចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៥ លើលិខិត១០៣២១ សហវ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សេចក្តីសម្រេចលេខ ០៣៩ កសក ចុះថ្ងៃទី២២ ខែ មករា ឆ្នាំ ២០១៤ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងចុះពិនិត្យ និងប្រមូលចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ច របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១:**

ត្រូវបានអនុញ្ញាតឱ្យគណៈកម្មការអន្តរក្រសួងដែលបំពេញភារកិច្ចផ្ទាល់ក្នុងការចុះពិនិត្យ វាយតម្លៃ និងជំរុញការបង់ចំណូលពីថ្លៃសម្បទានដីសេដ្ឋកិច្ច ដោយកាត់ទុកប្រាក់ចំណូលដែលបានពីការខិតខំប្រឹងប្រែងអនុវត្តកៀរគរចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចនេះ ក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ០៣% (បីភាគរយ) សម្រាប់ជាប្រាក់រង្វាន់លើកទឹកចិត្ត និងសម្រាប់ពង្រឹងយន្តការនៃការងារគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងនៅសល់ចំនួន៩៧%(កៅសិបប្រាំពីរភាគរយ) ត្រូវបង់ចូលថវិការដ្ឋ ។

**ប្រការ២:**

ប្រាក់រង្វាន់ចំនួន ០៣% (បីភាគរយ) នៃប្រាក់ចំណូលលើការខិតខំប្រឹងប្រែងអនុវត្តកៀរគរចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចនេះ ត្រូវបានបែងចែកដូចខាងក្រោម:

-ចំនួន ៥០ % (ហាសិបភាគរយ) ជាចំណែកលើកទឹកចិត្តមន្ត្រីបំពេញការងារ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងគណៈកម្មការ

-ចំនួន ៤០ % (សែសិបភាគរយ) ជាចំណែកលើកទឹកចិត្តមន្ត្រីបំពេញការងារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងគណៈកម្មការ

-ចំនួន ១០ % (ដប់ភាគរយ) សម្រាប់ចំណាយកិច្ចការចាំបាច់នានា ក្នុងគណៈកម្មការអន្តរក្រសួង ។

**ប្រការ៣:**

មុនពេលបង់ចំណូលពីថ្លៃសម្បទានដីសេដ្ឋកិច្ច ៩៧% ( កៅសិបប្រាំពីរភាគរយ) ចូលថវិការដ្ឋ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់លើកទឹកចិត្តចំនួន ០៣% (បីភាគរយ) គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ ដោយអនុញ្ញាតឱ្យដកយកភ្លាមៗពេលក្រុមហ៊ុនយកមកបង់ជូនរដ្ឋ ដើម្បីជាការលើកទឹកចិត្ត និងទិញមធ្យោបាយធ្វើដំណើរសម្រាប់បំពេញបេសកម្មចុះពិនិត្យ វាយតម្លៃ និងជំរុញការបង់ចំណូលពីថ្លៃសម្បទានដីសេដ្ឋកិច្ចចូលថវិការដ្ឋ ។ ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវបានចាត់ទុកថាថវិកាជាតិបានបើកផ្តល់ប្រាក់បុរេប្រទានជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់យកទៅបែងចែកដូចបានកំណត់ក្នុងប្រការ២ នៃប្រកាសនេះ ។ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធដែលបានទទួលប្រាក់រង្វាន់នេះ ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីរបស់ខ្លួន នៅរៀងរាល់ពេលដែលមានការបែងចែកប្រាក់រង្វាន់ ។

**ប្រការ៤:**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៥:**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ

ទាំងអស់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគណៈកម្មការអន្តរក្រសួងត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសអន្តរក្រសួងនេះ ចាប់ពីថ្ងៃទី០១ ខែ មករា ឆ្នាំ ២០១៥ តទៅ ។៚

រាជធានីភ្នំពេញ.ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**<u>កន្លែងទទួល:</u>**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងបរិស្ថាន
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-អាជ្ញាធរសវនកម្មជាតិ
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជូនជ្រាប"
-ដូចប្រការ៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ